សុន្ទរកថាដោយឯកឧត្តម HORINOUCHI Hidehisa
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន
ប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីផ្ទេរ-ប្រគល់សមិទ្ធផល និងសម្ពោធ
នៅខេត្តបាត់ដំបង ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

- សូមគោរព សម្តេច ក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សូមគោរព ឯកឧត្តម ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមពិធីផ្ទេរ-ប្រគល់សមិទ្ធផលដីចម្ការដែលបានបោសសម្អាតមីនហើយ និងបើកសម្ពោធគម្រោងបោសសម្អាតមីនថ្មី។

ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះសរដល់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានចំណាយពេលវេលាដ៏មមាញឹកចូលរួមក្នុងកម្មវិធីនេះ។

ខ្ញុំទទួលស្គាល់ពី សារៈសំខាន់នៃការបោសសម្អាតមីនក្នុងការថែរក្សាសុវត្ថិភាព របស់ប្រជាជន និងកសិករដែលរស់នៅធ្វើការនៅជុំវិញចម្ការមីន និងសារៈសំខាន់នៃការបោសសម្អាតមីននេះ ក្នុងការជួយដល់ការរីកចម្រើននៃសេដ្ឋកិច្ចតាមរយៈការអភិវឌ្ឍន៍ជនបទ។ រដ្ឋាភិបាលជប៉ុនគឺជាអ្នកគាំទ្រខ្លាំងក្នុងសកម្មភាពកំចាត់មីននៅកម្ពុជា តាំងពីឆ្នាំ1998មកម្ល៉េះ។ ទម្រង់នៃការគាំទ្ររបស់យើងមានច្រើនប្រភេទ ដូចជាការផ្តត់ផ្គង់សម្ភារៈបោសសម្អាតមីន ជំនួយបច្ចេកទេស ជំនួយហិរញ្ញវត្ថុសម្រាប់ចំនាយលើការងារប្រតិបត្តិការ និងការផ្តល់ជាជំនួយជួយដល់អង្គការមិនមែនរដ្ឋាភិបាលជាច្រើនដូចជា អង្គការ “JMAS” ជាដើម។

លទ្ធផលពីការបូកបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងរបស់ “CMAC” និង “JICS” ក្នុងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ និងកសិករក្នុងតំបន់ ខ្ញុំពិតជាមានសេចក្តីសប្បាយរីករាយយ៉ាងខ្លាំងនាថ្ងៃនេះ ដែលបានក្លាយជាសាក្សីក្នុងសមិទ្ធផលដ៏ជោគជ័យក្នុងការខិតខំប្រឹងប្រែងកំចាត់មីន និងការចាប់ផ្តើមនូវការបង្កើតផលិតផលកសិកម្មថ្មី។

ខ្ញុំក៏សង្ឃឹមផងដែរថា គម្រោងដំណាក់កាលទី3 នឹងជួយអោយ “CMAC” អាចធ្វើការងារប្រកបទៅដោយសុវត្ថិភាពជាងមុន និងមានប្រសិទ្ធភាពជាងមុន ក្នុងសកម្មភាពកំចាត់មីន ដោយសហការជាមួយនឹងភាគីពាក់ព័ន្ធ។ ខ្ញុំសង្ឃឹមយ៉ាងស្មោះសរថា ប្រជាជនកម្ពុជានឹងអស់ក្តីបារម្ភដោយអាចអនុវត្តការងារលើដីចម្ការដែលមានសុវត្ថិភាពជាងនេះ ក៏ដូចជាការធ្វើដំណើរទៅសាលាដោយមិនមានហានិភ័យគ្រោះថ្នាក់ដោយសារមីន។

តាំងនាមអោយរដ្ឋាភិបាលជប៉ុន ខ្ញុំសង្ឃឹមថា ជំនួយនេះនឹងជួយពង្រឹងទំនាក់ទំនងមិត្តភាពដ៏ជិតស្និទ្ធដែលមានស្រាប់រវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន។

សូមអរគុណ។